គំរោងបោសសំអាតមីនដើម្បីលទ្ធផល

Australian Government AusAID

DFID Department for International Development

UNDP Empowered lives. Resilient nations.

គោលបំណងនៃគម្រោង

គម្រោងបោសសំអាតមីនដើម្បីលទ្ធផលដំណាក់កាលទី ២ មានគោលបំណងជម្រុញស្ថាប័នថ្នាក់ជាតិ ពោលគឺ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) ឈានទៅមួយកម្រិតខ្ពស់ ថែមទៀត។ គម្រោងនេះនឹងគាំទ្រអាជ្ញាធរមីនក្នុងការដឹកនាំអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីន សំដៅធានាថា ធនធានបោសសំអាតមីនត្រូវបានតំរង់ទិសឆ្ពោះទៅរក អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ធនធានទាំងនេះក៏នឹងត្រូវបានប្រើប្រាស់ផងដែរសម្រាប់អនុវត្តគោលនយោបាយ ជម្រុញការរំដោះដីធ្លីពីគ្រាប់មីនជូនសហគមន៍សម្រាប់ការអភិវឌ្ឍជនបទដែលនឹងនាំទៅដល់ការបង្កើនលទ្ធភាព ឱកាសកំណើនសេដ្ឋកិច្ចផងដែរ។ សមត្ថភាពរបស់អាជ្ញាធរមីននៅថ្នាក់ស្ថាប័ន និងថ្នាក់បុគ្គលក្នុងផ្នែកមុខងារ និងបច្ចេកទេសត្រូវការកសាងបន្ថែមទៀត ដូចបានកំណត់រួចនៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពឆ្នាំ ២០១០។ អាជ្ញាធរមីនក៏នឹងមានតួនាទីគ្រប់គ្រងធនធានគម្រោងសម្រាប់ការបោសសំអាតមីនដែលធ្វើឱ្យខ្លួនទទួលបានមិនត្រឹមតែភាពជាម្ចាស់លើគម្រោងប៉ុណ្ណោះទេ ថែមទាំងបង្កើនភាពជាអ្នកដឹកនាំក្នុងវិស័យនេះផងដែរ។

សកម្មភាពសំខាន់ៗ

ដើម្បីសម្រេចផលនេះ គម្រោងនឹងអនុវត្តអភិក្រមបីមុខព្រួញ។

- មុខព្រួញទីមួយគម្រោងនឹងគាំទ្រដល់ការសម្របសម្រួលរួមនៃវិស័យនេះតាមរយៈ ការផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរមីនដើម្បីផ្សព្វផ្សាយ និងអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីន (២០១០-២០១៥)។ មុខព្រួញនេះនឹងគាំទ្រដល់លិខិតបទដ្ឋានផ្សេងៗ ដូចជា អនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- មុខព្រួញទី២ គម្រោងនឹងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់អាជ្ញាធរមីនដើម្បីគ្រប់គ្រងធ្វើនិយ័តកម្មសម្របសម្រួល និងត្រួតពិនិត្យវិស័យនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- មុខព្រួញចុងក្រោយបង្អស់គម្រោងនឹងបន្តបំពេញតួនាទីយ៉ាងសកម្មក្នុងការស្រាវជ្រាវ និងបោសសំអាតតំបន់មានមីន និងសំណង់យុទ្ធភ័ណ្ឌពីសង្គ្រាមដោយយកចិត្តទុកដាក់លើការជំរុញប្រសិទ្ធផល និងតម្លាភាពក្នុងការបង្កើនការរំដោះដីដែលមានមីនដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច។

លទ្ធផលសំខាន់ៗ

គម្រោងនេះ មានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ សំខាន់ៗតាមរយៈ:ក្រុមការងារបច្ចេកទេសសកម្មភាពមីន ស្របតាមគោលការណ៍ ស្តីពីប្រសិទ្ធភាពជំនួយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើនតម្លាភាព និងសុខដុមនីយកម្មធនធានដែលបានបែងចែកសម្រាប់វិស័យសកម្មភាពមីន។ លទ្ធផលសំខាន់ៗរំពឹងទុកសម្រាប់គម្រោងនេះមានដូចតទៅ :

១. គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រសកម្មភាពមីន ត្រូវធានាថា ធនធានទាំងអស់ត្រូវបានតំរង់ទិសប្រកបដោយស្រិទ្ធភាព ឆ្ពោះទៅរកអាទិភាពជាតិ ដូចបានកំណត់ក្នុងដំណើរការកសាងផែនការថ្នាក់មូលដ្ឋាន និងបង្កើនដីធ្លីសម្រាប់ការអភិវឌ្ឍមូលដ្ឋានឱ្យបានច្រើនជាអតិបរមា។

២. អាជ្ញាធរមីននឹងមានសមត្ថភាពបច្ចេកទេស និងមុខងារដែលចាំបាច់ដើម្បីគ្រប់គ្រងសម្របសម្រួលធ្វើនិយ័តកម្ម និងត្រួតពិនិត្យវិស័យសកម្មភាពមីនក្នុងបរិយាកាសដែលមានការវិវឌ្ឍជានិច្ច។

៣. យ៉ាងហោចណាស់ផ្ទៃដីដែលមានមីន៣៥គីឡូម៉ែត្រក្រឡានឹងត្រូវបានស្រាវជ្រាវ កត់ត្រាបោសសំអាត និងរំដោះសម្រាប់ការប្រើប្រាស់បង្កបង្កើតផល តាមរយៈ ការកសាងផែនការថ្នាក់មូលដ្ឋានដែលជំរុញឱ្យមានប្រសិទ្ធភាព និងតម្លាភាព។

ការប្រគល់គម្រោងនេះទៅអោយអាជ្ញាធរមីនគ្រប់គ្រងដឹកនាំ និងអនុវត្ត គួបផ្សំនឹងគំនិតផ្តួចផ្តើមអភិវឌ្ឍសមត្ថភាពរបស់អាជ្ញាធរមីនផងនោះនឹងនាំឱ្យអាជ្ញាធរមីនមានការទទួលខុសត្រូវខ្ពស់ថែមទៀត ដើម្បីគ្រប់គ្រងធនធានដែលបានបែងចែកដល់

វិស័យនេះក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍន៍មូលដ្ឋាន។ ទីបំផុត នៅចុងបញ្ចប់នៃគម្រោងអាជ្ញាធរមីននឹងមានសមត្ថភាពរកឃើញនូវចំណុចខ្វះចន្លោះក្នុងការគ្រប់គ្រងវិស័យសកម្មភាពមីន និងអាចរកដំណោះស្រាយជាសកម្មភាពក្តីភាពជាដៃគូក្តី ឬជាធនធានដែលត្រូវការចាំបាច់ក្តីដើម្បីដោះស្រាយចំណុចខ្វះចន្លោះទាំងនេះដោយពុំត្រូវការឬត្រូវការការជ្រើមជ្រែងតិចតួចពី UNDP ។

សាវតារ

បន្ទាប់ពីមានសង្គ្រាម និងជម្លោះផ្ទៃក្នុងអស់ជិតបីទសវត្សរ៍កម្ពុជានៅតែទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារមីន និងសំណល់យុទ្ធភ័ណ្ឌពីសង្គ្រាម។ នៅឆ្នាំ២០០៣ កម្ពុជាបានអនុម័តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៩ ដែលមានលក្ខណៈពិសេសដើម្បីបោសសំអាតដីមានមីនទាំងអស់ដើម្បីកាត់បន្ថយអត្រាគ្រោះថ្នាក់អោយដល់កម្រិតសូន្យ និងដើម្បីកែលម្អការនួយសង្គ្រោះជនរងគ្រោះនៅត្រឹមឆ្នាំ ២០១៥។ រដ្ឋាភិបាលបានប៉ាន់ប្រមាណថា មានផ្ទៃដីប្រមាណជា ៦៤៩ គីឡូម៉ែត្រក្រឡាត្រូវការការបោសសំអាតមីននៅរយៈពេលពី ១០ ទៅ ១៣ឆ្នាំ បន្ទាប់។ ការស្រាវជ្រាវមូលដ្ឋានដែលកំពុងត្រូវបានអនុវត្តតាំង ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ នឹងកំណត់បានកាន់តែច្បាស់នូវទំហំ និងទីតាំងដែលត្រូវការបោសសំអាតកំណត់បាននូវរបៀបវារៈសម្រាប់សកម្មភាពមីននៅកម្ពុជារហូតដល់ឆ្នាំ ២០១៩។

ការណ៍ និងតួលេខ

រយៈពេល

២០១១-២០១៥

ធនធានសរុបដែលត្រូវការ (ខែមិនា ឆ្នាំ២០១១)

២៤.១៥២.៦៤០ ដុល្លារអាមេរិក

ម្ចាស់អំណោយដែលរួមចំណែក

UNDP: ១.000.000 ដុល្លារអាមេរិក
CIDA: ១0.000.000 ដុល្លារកាណាដា
AusAID: ១0.000.000 ដុល្លារអូស្ត្រាលី
(៦.២លានដុល្លារអូស្ត្រាលីសំរាប់រយៈពេល ២០១១-២០១៣)
DFID: ២៧៦.៨៥៨ផោនអង់គ្លេស (សំរាប់រយៈពេល២០១១-២០១២)
ដៃគូអនុវត្ត : អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និងអ្នកដេញថ្លៃទទួលបានជោគជ័យ

ទីតាំង:

ភ្នំពេញ និងតំបន់ផ្សេងៗនៃប្រទេសកម្ពុជាដែលរងគ្រោះសារមីន និងសំណល់យុទ្ធភ័ណ្ឌពីសង្គ្រាម។

គោលដៅអភិវឌ្ឍន៍សហស្សវត្ស

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទី៩ : ការបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយជនរងគ្រោះ

កម្មវិធីប្រចាំប្រទេសរបស់ UNDP

លទ្ធផលទី១សម្រាប់រយៈពេលមធ្យម : នៅឆ្នាំ ២០១៥ សមត្ថភាពថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវបានពង្រឹងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យកាន់តែមានភាពចម្រុះ និរន្តរភាព និងសមធម៌។
លទ្ធផលទី២រយៈពេលខ្លី : រចនាសម្ព័ន្ធ និងយន្តការថ្នាក់ជាតិធានាថា ធនធានសម្រាប់ការបោសសំអាតមីនត្រូវបានតំរង់ទិសប្រកបដោយប្រសិទ្ធភាពដើម្បីជំរុញដល់ការរំដោះដីសម្រាប់ការប្រើប្រាស់បង្កបង្កើនផលដោយជនក្រីក្រ។

ទិសដៅតាមមូលបទរបស់ UNDP

ការកាត់បន្ថយភាពក្រីក្រ

ទំនាក់ទំនង

ជនបង្គោលរបស់ UNDP
អ្នកស្រី Melissa SABATIER ទីប្រឹក្សាគម្រោង
UNDP, អគារលេខ ៥៣ ផ្លូវលេខ ៥១ រាជធានីភ្នំពេញ
ទូរស័ព្ទ : + ៨៥៥ (0) ២៣ ២១៦ ១៦៧
អ៊ីម៉ែល : melissa.sabatier@undp.org
គេហទំព័រ: www.un.org.kh/undp/

សមភាគីថ្នាក់ជាតិ

ឯកឧត្តម ជុំ ប៊ុន រុង អគ្គលេខាធិការ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
ផ្លូវលេខ ២៧៣ និង ៥១៦ ភូមិទួលគោក សង្កាត់ទួលសង្កែ រាជធានីភ្នំពេញ
ទូរស័ព្ទ: +៨៥៥ (0) ២៣ ៨៨0 ៤6២
អ៊ីម៉ែល: chumbunrong@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh
ធ្វើបច្ចុប្បន្នភាព : ខែមិថុនា ឆ្នាំ២០១១
រូបថត : UNDP / Nathan Horton